ភាសាខ្មែរៈអំណាន

ប្រាសាទព្រះវិហារ

I.ចូរអានអត្ថបទរួចឆ្លើយនឹងសំណួរៈ

ប្រាសាទព្រះវិហារ ឋិតនៅយ៉ាងខ្ពស់ត្រដែត លើកំពូលរាបស្មើនៃជួរភ្នំដងរែក ក្នុងខេត្តព្រះវិហារ ។ ប្រាសាទនេះ បានសាងសង់ឡើងនៅចុងសតវត្សរ៍ទី ៩ ប្រកបដោយក្បូរក្បាច់រចនាដ៏ប្រណីត ។

នៅថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០០៨ ប្រជាជនទូទាំងប្រទេសមានទឹកមុខសប្បាយរីករាយឥតឧបមា ។ ក្រោមការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រាសាទព្រះវិហារដែលជាកេរមរតករបស់ខ្មែរ ត្រូវបានអង្គការយូនីស្កូយល់ព្រមដាក់បញ្ចូលក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោក ។

ក្នុងថ្ងៃដដែលនោះ គ្រប់ក្រសួង មន្ទីរ សាលារៀនបានប្រមូលផ្តុំគ្នា នៅជងទង់ជាតិ ដើម្បីច្រៀងចម្រៀងជាតិ និងបង្ហូតទង់ជាតិ ហើយនិងស្តាប់សាររបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាល ដែលចាក់ផ្សាយតាមវិទ្យុ ទូរទស្សន៍ជាសាធារណៈ ។ ឯទីវត្តអារាម ព្រះសង្ឃបានវាយស្គរ និងសូត្រជយន្តោប្រសិទ្ធពរជ័យក្នុងឱកាសនោះដែរ ។

រយៈពេលប៉ុន្មានខែក្រោយមក ក្រោមមូលនិធិទូរទស្សន៍បាយ័ន និងអំណោយរបស់សប្បុរសជន គេបានកសាងផ្លូវចាក់បេតុងមួយខ្សែយ៉ាងប្រណីត គួរឱ្យស្ញើចសរសើរទៅកាន់ប្រាសាទព្រះវិហារ ដែលធ្វើឱ្យយើងងាយស្រួលក្នុងការធ្វើដំណើរទៅកាន់ទីនោះ ។

សមិទ្ធផលទាំងនេះ បានមកពីកម្លាំងសាមគ្គីដ៏ស្អិតរមួតរបស់ប្រជាជនខ្មែរយើង ។ អំណឹះតទៅ យើងត្រូវតែប្តេជ្ញាការពារសម្បត្តិបេតិកភណ្ឌពិភពលោកឱ្យបានឋិតថេរចីរកាលជានិរន្តរ៍ ។

II. ចូរផ្គូផ្គងពាក្យ កន្សោមពាក្យ ទៅថ្នាក់ពាក្យ សេចក្តីពន្យល់ឱ្យបានជាចម្លើយត្រឹមត្រូវៈ

| ពាក្យ កន្សោមពាក្យ | ថ្នាក់ពាក្យ និងសេចក្តីពន្យល់ |
|---|---|
| ១. មូលនិធិ | - (គុ.):ដែលជាទូទៅ ជាកណ្តាល ដែលប្រើបានទាំងអស់គ្នា។ |
| ២. សាធារណៈ | - (ន.):កំណប់ទ្រព្យដើម។ |
| ៣. សប្បុរសជន | - (ន.): ពាក្យសម្រាប់ឱ្យពរជ័យ ឱ្យមានជ័យជម្នះ។ |
| ៤. ជយន្តោ | - (ន.): អ្នកប្រព្រឹត្តល្អដោយកាយវាចាចិត្ត។ |

III. ចូររកបដិសព្ទ(ពាក្យផ្ទុយ) ខាងក្រោមឱ្យបានត្រឹមត្រូវៈ

១. សាមគ្គី ≠ [ ] ,សរសើរ ≠ [ ]

២. ការពារ ≠ [ ] ,ឋិតថេរ ≠ [ ]

LIVEWORKSHEETS

IV. ចូររៀបចំសព្ទ(ពាក្យន័យដូច) នឹងពាក្យ «កសាង ,រីករាយ»ឱ្យបានត្រឹមត្រូវ៖

១. កសាង: ធ្វើ បំផ្លាញ បង្កើត កម្ទេច សាងសង់ ស្ថាបនា

២. រីករាយ: ត្រេកអរ កើតទុក្ខ សប្បាយ ឆ្គួរសម សោមនស្ស

V. ចូរជ្រើសរើសថ្នាក់ពាក្យ និងសេចក្ដីពន្យល់នៃសទិសសព្ទ(ពាក្យសូរដូច)នឹងពាក្យ «ក៏»៖

១. វាត់៖ ........................................................................................................

២. វត្ត៖ ........................................................................................................

៣. វដ្ដ៖ ........................................................................................................

VI. ចូរឆ្លើយនឹងសំណួរខាងក្រោមឱ្យបានត្រឹមត្រូវ៖

១.តើប្រាសាទព្រះវិហារ ត្រូវបានបញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកនៅថ្ងៃណា ? ខែណា? ឆ្នាំណា?

........................................................................................................

........................................................................................................

........................................................................................................

២. តើរាជរដ្ឋាភិបាលបញ្ចូលប្រាសាទនេះ ជាសម្បត្តិបេតិកភណ្ឌពិភពលោកដើម្បីអ្វី?

........................................................................................................

........................................................................................................

........................................................................................................

៣.តើអ្នកត្រូវធ្វើដូចម្ដេច ដើម្បីឱ្យប្រាសាទព្រះវិហារនៅគង់វង្សឋិតថេរចីរកាលតទៅ?

........................................................................................................

........................................................................................................

........................................................................................................

LIVEWORKSHEETS